# កំណាព្យ

## ម្លិះម៉ិញសព្វដង

### បទមេបួន

ម្លិលម៉ិញពៅសួន ញញឹមស្នេហ៍ផ្អែម ញញឹមប្រាប់ថែម ថាមានតែយើង
អូននិងបងសាង ស្នេហាជារឿង ខ្លឹមចិត្តផ្សំគ្រឿង សម្ងាត់បេះដូង។
ម្លិលម៉ិញកែវភ្នែក ស្រទន់ដាក់បង ក្នុងគោលបំណង បញ្ជាក់ស្រឡាញ់
រកចម្លើយស្នេហ៍ ពីប្ដីសម្លាញ់ កុំមានចិត្តក្ដាញ់ រអែងស្នេហា។
ម្លិលម៉ិញភ្លៅរៀម ជាខ្នើយកេសា ចិត្តពៅប្រាថ្នា ចងស្នេហ៍ទិព្វមន្ត
ភ្ជុំចិត្តភក្ដី មានចិញ្ចៀនពុម្ព បោះត្រាសម្ពង្ស[1] អាពាហ៍ពិពាហ៍។
ម្លិលម៉ិញបងរៀប រាប់ប្រាប់ទឹកចិត្ត ថាប្ដីស្នេហ៍ពិត ពៅម្ចាស់ជីវា
ចំណងស្នេហា គ្មានក្ដីរំខាន ពីគ្រប់មជ្ឈដ្ឋាន ព្រោះចិត្តស្មោះត្រង់។
ម្លិលម៉ិញតែមួយ គ្មានថ្ងៃស្អែកប្ដូរ រូបភាពសម្បូណ៌ តែក្ដីមង្គល
ឆ្លាក់លើចិន្ដា សិលាមណ្ឌល តម្កល់ស្នេហ៍គង់ លើហ៊ុង[2]ទេព្ដា។
ជាថ្នាលបេតី មិនអាចរសាយ តាមចរន្ដកាយ គ្រប់វ័យនរៈ[3]
កាលមានតែមួយ គឺស្នេហ៍សច្ចៈ តាមចរណៈ[4] ម្លិលម៉ិញសព្វដង។

ប្រើវចនានុក្រមខ្មែររបស់ពុទ្ធសាសនាបណ្ឌិត្យ



---

[1] សម្ពង្ស (សំ ពង់) : ការបានគ្នាជាស្វាមីភរិយា។
[2] ហ៊ុង : កំណាត់ក្ដារចងបន្ទាងផ្ទប់នឹងជញ្ជាំងសំរាប់ដាក់អ្វីៗ។
[3] នរៈ : មនុស្ស។
[4] ចរណៈ (អាន ចៈ រៈ ណៈ) : សេចក្ដីប្រព្រឹត្តល្អ។

**ឧប សៅ សុទ្ធា** **កម្រងកំណាព្យ** **២៧ វិច្ឆិកា ២០២០**